Washington State
Department of Social & Health Services

DDA Developmental Disabilities Administration

# កម្មវិធីវាយតម្លៃ របស់ Developmental Disabilities Administration

**ពត៌មានសម្រាប់ប្រជាពលរដ្ឋ ដែលមានពិការភាពពីកំណើតឬពីក្មេងវ័យ**

## តើកម្មវិធីវាយតម្លៃ DDA ជាអ្វី?

កម្មវិធីវាយតម្លៃរបស់នាយកដ្ឋានអភិវឌ្ឍន៍ពិការភាព (Developmental Disabilities Administration (DDA) Assessment) គឺជាកម្រងសំណួរ ដែលនាយកគ្រប់គ្រងសំណុំរឿងរបស់លោកអ្នក នឹងសួរលោកអ្នក ដើម្បីជួយកំណត់មើលថាតើលោកអ្នកត្រូវការសេវាឧបត្ថម្ភប្រភេទណាខ្លះ។ វាគឺជាមធ្យោបាយមួយ ដែលជួយនាយកដ្ឋាន DDA ក្នុងការបំពេញមុខងារល្អបំផុត តាម ដែលពួកគេអាចធ្វើទៅបាន ជូនលោកអ្នក។

## កម្មវិធីវាយតម្លៃ DDA មានបីផ្នែក ៖

1. ផ្នែកទីមួយនៃការវាយតម្លៃនេះសួរសំណួរអំពីការឧបត្ថម្ភ ដែលលោកអ្នកត្រូវការ ដើម្បីរស់នៅក្នុងសហគមន៍ និងដើម្បីចូលរួមសកម្មភាពនានា ដែលមនុស្សម្នាគ្រប់គ្នាធ្វើ។

2. ផ្នែកទីពីរសួរសំណួរអំពីជំនួយ ដែលលោកអ្នកត្រូវការក្នុងការថែទាំផ្ទាល់ខ្លួន និងការចូលរួមសកម្មភាពរស់នៅប្រចាំថ្ងៃ ដូចជាការបរិភោគចំណីអាហារ, ការងូតទឹក, ការស្លៀកពាក់ជាដើម ។ល។

3. ផ្នែកទីបីគឺជាផែនការ ដែលពន្យល់ប្រាប់អំពីការឧបត្ថម្ភ និងសេវាកម្មនានា ដែលលោកអ្នកនឹងទទួលបាន ហើយនិងថាតើនរណានឹងផ្តល់ការឧបត្ថម្ភទាំងនេះជូនលោកអ្នក។

## តើខ្ញុំនឹងទទួលកម្មវិធីវាយតម្លៃ DDA នៅពេលណា?

លោកអ្នកនឹងទទួលការវាយតម្លៃ នៅមុនពេលលោកអ្នកចាប់ផ្តើមទទួលសេវាកម្មពីនាយកដ្ឋានអភិវឌ្ឍន៍ពិការភាព។ បើលោកអ្នកបាននិងកំពុងទទួលសេវាកម្មរួចទៅហើយ នោះលោកអ្នកនឹងត្រូវទទួលការវាយតម្លៃថ្មីទៀតជារៀងរាល់ឆ្នាំ។

## ហេតុអ្វីអ្នកគ្រប់គ្រងសំណុំរឿងរបស់ខ្ញុំប្រើកម្មវិធីវាយតម្លៃ DDA?

DDA ចង់សួរប្រជាពលរដ្ឋគ្រប់រូបនូវសំណួរដូចៗគ្នា។ នាយកគ្រប់គ្រងសំណុំរឿងប្រើកុំព្យូទ័រ ដើម្បីជួយស្មារតីរបស់ពួកគេ ឲ្យនឹកឃើញគ្រប់ទាំងសំណួរសំខាន់ៗ ដែលពួកគេត្រូវសួរលោកអ្នក ហើយកត់ចម្លើយរបស់លោកអ្នកទុក។ ការនេះនឹងជួយ DDA ធ្វើយ៉ាងណាឲ្យប្រាកដថា សមត្ថភាពរបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានវាស់ស្ទង់ដូចៗគ្នាទាំងអស់ ហើយឥតមានអ្វីណាមួយត្រូវពួកគេរំលងចោលនោះឡើយ។

## តើនេះមានន័យយ៉ាងដូចម្តេចសម្រាប់ខ្ញុំ?

កម្មវិធីវាយតម្លៃ DDA នឹងជួយនាយកគ្រប់គ្រងសំណុំរឿងរបស់លោកអ្នក ឲ្យស្វែងយល់អំពីសមត្ថភាពរបស់លោកអ្នក និងអំពីអ្វីដែលត្រូវការ ដើម្បីជួយលោកអ្នកក្នុងការរៀបចំផែនការសម្រាប់អនាគត។

## តើខ្ញុំអាចនឹងធ្វើការវាយតម្លៃនេះមិនជាប់ទេ?

ទេ, ការវាយតម្លៃនេះមិនដែលធ្លាក់ទេ។ ការវាយតម្លៃ DDA ធ្វើឡើង ដើម្បីស្វែងយល់អំពីលោកអ្នក និងសមត្ថភាពនិងតម្រូវការរបស់លោកអ្នក។ ឥតមានចម្លើយត្រូវឬខុសនៅក្នុងការវាយតម្លៃនេះនោះឡើយ, វាមានតែចម្លើយរបស់លោកអ្នកប៉ុណ្ណោះ។

## ចុះបើខ្ញុំមិនយល់សំណួរ?

លោកអ្នកអាចរកនរណាម្នាក់ ឲ្យមកជាមួយលោកអ្នក ដើម្បីជួយឆ្លើយសំណួរជូនលោកអ្នក។ លោកអ្នកអាចជ្រើសរើសមនុស្សណាក៏បាន ទៅតាមចំណូលចិត្តរបស់លោកអ្នក។ បើលោកអ្នកមានអាណាព្យាបាល នោះលោកអ្នកអាចអញ្ជើញអាណាព្យាបាលរូបនោះ ឲ្យមកចូលរួមប្រជុំវាយតម្លៃជាមួយលោកអ្នកក៏បាន។

## តើវានឹងប្រើពេលយូរប៉ុណ្ណា?

ការវាយតម្លៃ DDA នឹងប្រើពេលពី 2 ទៅ 4 ម៉ោង។ បើវាប្រើពេលយូរពេកសម្រាប់លោកអ្នក នោះលោកអ្នកអាចសុំនាយកគ្រប់គ្រងសំណុំរឿងរបស់លោកអ្នក ឲ្យបំបែកធ្វើមួយថ្ងៃមួយផ្នែកនេះ ហើយមួយថ្ងៃទៀតមួយផ្នែកនោះ។

## ចុះបើខ្ញុំមិនចង់ឆ្លើយសំណួរ?

លោកអ្នកអាចជ្រើសរើសមិនឆ្លើយនឹងសំណួរទាំងឡាយនោះបាន ក៏ប៉ុន្តែបើលោកអ្នកចង់បានជំនួយពីនាយកដ្ឋាន DDA នោះ លោកអ្នក ឬអ្នកតំណាងរបស់លោកអ្នកចាំបាច់ត្រូវតែឆ្លើយនឹងសំណួរទាំងអស់នោះ។

## នៅក្រោយពេលខ្ញុំឆ្លើយសំណួរទាំងអស់ហើយ តើនឹងមានអ្វីកើតឡើង?

នៅក្រោយពេលលោកអ្នកឆ្លើយសំណួរទាំងអស់ហើយ នោះនាយកគ្រប់គ្រងសំណុំរឿងរបស់លោកអ្នកនឹងជួយលោកអ្នក រៀបចំផែនការមួយសម្រាប់ឆ្នាំក្រោយ។ ផែនការនេះនឹងពន្យល់ប្រាប់លោកអ្នកអំពីសេវាកម្ម និងការឧបត្ថម្ភនានា ដែលលោកអ្នកនឹងទទួលបាន ហើយនិងថាតើនរណានឹងផ្តល់សេវាឧបត្ថម្ភទាំងនោះជូនលោកអ្នក។ នាយកគ្រប់គ្រងសំណុំរឿងរបស់លោកអ្នកនឹងផ្តល់សំណៅចម្លងនៃផែនការនេះមួយច្បាប់ ជូនលោកអ្នក។

## ចុះបើខ្ញុំមិនចូលចិត្តផែនការរបស់ខ្ញុំ?

នាយកគ្រប់គ្រងសំណុំរឿងរបស់លោកអ្នកនឹងពន្យល់ប្រាប់លោកអ្នកថា លោកអ្នកមានសិទ្ធិស្នើសុំឧទ្ធរណ៍ ដែលនេះមានន័យថា លោកអ្នកអាចប្រាប់នៅជនផ្សេងទៀតអំពីមូលហេតុ ដែលលោកអ្នកមិនយល់ស្របតាមផែនការនេះ។ ជនដែលពិនិត្យមើលបណ្តឹងឧទ្ធរណ៍របស់លោកអ្នកនឹងធ្វើសេចក្តីសម្រេច ថាតើគេនឹងត្រូវធ្វើអ្វីបន្ទាប់ទៀត។

## ចុះបើខ្ញុំត្រូវធ្វើការផ្លាស់ប្តូរ?

បើសិនជាតម្រូវការរបស់លោកអ្នកមានការប្រែប្រួល នោះនាយកគ្រប់គ្រងសំណុំរឿងរបស់លោកអ្នកនឹងដាក់ពេលណាត់ជួបមួយ ដើម្បីជម្រាបប្រាប់លោកអ្នក ឲ្យបានជ្រាបអំពីពត៌មានពាក់ព័ន្ធថ្មីៗទៀត។

## ចុះបើខ្ញុំនៅតែមានសំណួរអំពីការវាយតម្លៃ **DDA** ថ្មី?

*សូមទូរស័ព្ទទាក់ទងនាយកគ្រប់គ្រងសំណុំរឿងរបស់លោកអ្នក ឬសូមចូលមើលគេហទំព័រនៃកម្មវិធីវាយតម្លៃ DDA នៅ ៖*
**www.dshs.wa.gov/ddd/CAP.shtml**